ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ករណីឆបោកសមាជិក ប.ស.ស. តាមរយៈការផ្សព្វផ្សាយ លេខគណនីធនាគារក្លែងក្លាយរបស់បេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង QR Code ផ្ទេរប្រាក់ក្លែងក្លាយ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សមាជិក ប.ស.ស. និងសាធារណជន មេត្តាជ្រាបថា នាពេលថ្មីៗនេះ មានជនអនាមិកបានបន្លំខ្លួនជាមន្ត្រី ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយប្រើប្រាស់រូបថត និងនិមិត្តសញ្ញា ប.ស.ស. ទាក់ទងទៅកាន់សមាជិកដោយផ្ទាល់ ដែលបានភ្ជាប់នូវលេខគណនីធនាគារក្លែងក្លាយរបស់ ប.ស.ស. និង QR Code ផ្ទេរប្រាក់ក្លែងក្លាយ ដែលនាំឱ្យមានការភាន់ច្រឡំ និងធ្វើឱ្យខាតបង់ថវិការបស់សមាជិក ប.ស.ស. ដែលត្រូវបង់ភាគទានរបបសន្តិសុខសង្គមមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្នុងន័យនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមបញ្ជាក់ជូន ដូចខាងក្រោម៖

១. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនមានគោលការណ៍ឱ្យមន្ត្រី ប.ស.ស. ផ្សព្វផ្សាយលេខគណនីធនាគារផ្ទាល់ខ្លួនទៅសមាជិក ប.ស.ស. នោះទេ ក្រៅពីការផ្តល់ព័ត៌មានតាមរយៈប្រព័ន្ធ **Hotline** លេខ “**១២៨៦**” ឬ “**១២៩៧**” ឬ Facebook Page ឬ Telegram ផ្លូវការ https://t.me/nssfcambodia_Chat តែប៉ុណ្ណោះ។

២. ការបង់ភាគទាន ប.ស.ស. មិនមានការប្រើប្រាស់ QR Code ដើម្បីផ្ទេរប្រាក់ចូលមកលេខគណនី ប.ស.ស. នោះឡើយ។ ការបង់ភាគទាន ត្រូវធ្វើឡើងតាមរយៈ App ផ្លូវការរបស់ធនាគារដៃគូ ដោយចូលទៅមីនុយ (Menu) ទូទាត់ រួចធ្វើការបង់ប្រាក់សេវាសាធារណៈដែលមាននិមិត្តសញ្ញា ប.ស.ស. ឬត្រូវបង់ចូលគណនីធនាគាររបស់ ប.ស.ស. ដោយផ្ទាល់នៅតាមទីស្នាក់ការធនាគារដៃគូ។

ក្នុងករណីមានការសង្ស័យណាមួយ ឬសួរនាំព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ប្រព័ន្ធ **Hotline** លេខ “**១២៨៦**” ឬ “**១២៩៧**” ឬ Facebook Page ឬ Telegram ផ្លូវការ https://t.me/nssfcambodia_Chat ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសមាជិក ប.ស.ស. និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងសូមប្រុងប្រយ័ត្នចំពោះករណីក្លែងបន្លំនេះ។

ថ្ងៃចន្ទ ១៣រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៤

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩